**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
អគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក

សេចក្តីប្រកាសព័ត៌មាន

# លទ្ធផលនៃកិច្ចពិគ្រោះយោបល់នយោបាយលើកទី២ រវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា និងក្រសួងការបរទេសសិង្ហបុរី ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៥ នៅប្រទេសសិង្ហបុរី

នៅព្រឹកថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម ថៃ ផុន អនុរដ្ឋលេខាធិការបានអញ្ជើញធ្វើជាសហប្រធានដឹកនាំកិច្ចពិគ្រោះយោបល់នយោបាយលើកទី២ រវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ កម្ពុជា និងក្រសួងការបរទេសសិង្ហបុរី ជាមួយលោកជំទាវ ហ្វ៊ូ ឈីស៊ា អគ្គលេខាធិការរងនៃក្រសួងការបរទេសសិង្ហបុរី។ កិច្ចប្រជុំត្រូវបានបញ្ចប់ដោយទទួលបានលទ្ធផលប្រកបដោយផ្លែផ្កា និងពង្រឹងការប្តេជ្ញាចិត្តរវាងកម្ពុជា និងសិង្ហបុរី ក្នុងការធ្វើឱ្យទំនាក់ទំនងទ្វេភាគីកាន់តែស៊ីជម្រៅ ស្របពេលដែលប្រទេសទាំងពីរប្រារព្ធខួបអនុស្សាវរីយ៍លើកទី៦០ នៃការបង្កើតទំនាក់ទំនងការទូត។

សហប្រធានទាំងពីរបានធ្វើការផ្លាស់ប្តូរទស្សនលើកិច្ចសហប្រតិបត្តិការក្នុងវិស័យជាច្រើន រួមមាន សន្តិសុខ-នយោបាយ, ការពារជាតិ, ពាណិជ្ជកម្ម និងវិនិយោគ, ទេសចរណ៍, ការអភិវឌ្ឍធនធានមនុស្ស, ហិរញ្ញវត្ថុ និងរដ្ឋាភិបាលឌីជីថល, សន្តិសុខស្បៀង និងថាមពល។ សហប្រធានទាំងពីរបានរំលឹកអំពីការដឹកនាំប្រកបដោយចក្ខុវិស័យ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ និងអតីតនាយករដ្ឋមន្ត្រីសិង្ហបុរី ឯកឧត្តម លី ក្វាន់យូ ដែលបានបង្កើតមូលដ្ឋានដ៏រឹងមាំសម្រាប់ទំនាក់ទំនងមិត្តភាពរវាងកម្ពុជា និងសិង្ហបុរី និងប្តេជ្ញាធានាបាននូវភាពជោគជ័យនៃដំណើរទស្សនកិច្ចផ្លូវការរបស់ឯកឧត្តមនាយករដ្ឋមន្ត្រី ឡរ៉េន វ៉ុង នៅព្រះរាជាណាចក្រកម្ពុជា។

ចំពោះកិច្ចសហប្រតិបត្តិការលើវិស័យការពារជាតិ និងសន្តិសុខ ភាគីទាំងពីរបានគូសបញ្ជាក់ពីសារៈសំខាន់នៃការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលារវាងភ្នាក់ងារអនុវត្តច្បាប់នៃប្រទេសទាំងពីរក្នុងការដោះស្រាយឧក្រិដ្ឋកម្មឆ្លងដែន។ សហប្រធានទាំងពីរ បានសង្កត់ធ្ងន់ពាក់ព័ន្ធនឹងការជំរុញកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធតាមរយៈការចែករំលែកព័ត៌មាន ការធ្វើប្រតិបត្តិការរួមគ្នា និងការកសាងសមត្ថភាព ដែលរួមចំណែកដល់សន្តិសុខតំបន់ ស្ថិរភាព និងសុវត្ថិភាពសាធារណៈឱ្យកាន់តែប្រសើរឡើង។

សហប្រធានទាំងពីរបានប្តេជ្ញាលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរព័ត៌មាន និងកិច្ចសន្ទនាជាប្រចាំ ដើម្បីរិះរកកាលានុវត្តភាពបង្កើនពាណិជ្ជកម្មទ្វេភាគី និងវិនិយោគ រវាងកម្ពុជា និងសិង្ហបុរី ជាពិសេសនៅក្នុងវិស័យកសិកម្ម និងផលិតកម្មស្បៀង។ ភាគីទាំងពីរបានកោតសរសើរអំពីការវិវត្តជាវិជ្ជមាននៃថ្នាលប្រកួតប្រជែងតម្លាភាពហិរញ្ញវត្ថុ និងអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការរដ្ឋាភិបាលឌីជីថល ដែលត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ និងចុះហត្ថលេខាកាលពីឆ្នាំមុន ក្នុងឱកាសទស្សនកិច្ចផ្លូវការរបស់សម្តេចធិបតី នៅប្រទេសសិង្ហបុរី។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល: mfaic@mfaic.gov.kh

ដោយទទួលស្គាល់អំពីសក្តានុពលក្នុងវិស័យទេសចរណ៍ និងការផ្លាស់ប្តូររវាងប្រជាជន និងប្រជាជន សហប្រធានទាំងពីរបានលើកទឹកចិត្តដល់ភ្នាក់ងារទេសចរណ៍នៃប្រទេសទាំងពីរធ្វើការជិតស្និទ្ធជាមួយគ្នា ដើម្បីឈានដល់ការបង្កើតក្រុមការងារបច្ចេកទេសចម្រុះលើវិស័យទេសចរណ៍ ដើម្បីរិះរកការអភិវឌ្ឍកញ្ចប់ទេសចរណ៍រួម និងកម្មវិធីប្រូម៉ូសិន ក៏ដូចជាបន្ថែមជើងហោះហើរទៅកាន់តំបន់ទេសចរណ៍សំខាន់ៗរវាងកម្ពុជា និងសិង្ហបុរី។

សហប្រធានបានប្តេជ្ញាពន្លឿនធ្វើឱ្យចេញជារូបរាងនូវគោលបំណងនៃការតភ្ជាប់ថាមពល ដែលបានព្រមព្រៀងនៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីថាមពលកម្ពុជា-ឡាវ-សិង្ហបុរី លើកទី១ ស្តីពីពាណិជ្ជកម្មថាមពលអគ្គិសនី កាលពីខែឧសភា ឆ្នាំ២០២៤ នៅប្រទេសសិង្ហបុរី។

ពាក់ព័ន្ធនឹងការអភិវឌ្ឍធនធានមនុស្ស ភាគីទាំងពីរបានគូសបញ្ជាក់អំពីសារៈសំខាន់នៃការបន្តកិច្ចសហប្រតិបត្តិការ និងការរួមបញ្ចូលប្រធានបទពាក់ព័ន្ធ ដូចជា សុវត្ថិភាពអាកាសចរណ៍ជាដើម។ ក្នុងន័យនេះ ឯកឧត្តម ថៃ ជុន បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាលសិង្ហបុរី ក្នុងការបន្តគាំទ្រដោយផ្តល់វគ្គបណ្តុះបណ្តាលដល់មន្ត្រីកម្ពុជា ទាំងក្រោមកម្មវិធីកិច្ចសហប្រតិបត្តិការសិង្ហបុរី (SCP) និងក្រោមគំនិតផ្តួចផ្តើមសម្រាប់សមាហរណកម្មអាស៊ាន (IAI)។

ចំពោះកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងលើឆាកអន្តរជាតិ រួមទាំងក្របខ័ណ្ឌអង្គការសហប្រជាជាតិ និងអាស៊ាន ភាគីទាំងពីរបានបញ្ជាក់សាជាថ្មីអំពីឆន្ទៈ ក្នុងការរក្សានូវកិច្ចសហប្រតិបត្តិការល្អដែលមានស្រាប់រវាងប្រទេសទាំងពីរ និងបន្តពង្រឹងកិច្ចសហប្រតិបត្តិការពហុភាគី។

ភាគីទាំងពីរបានឯកភាពនឹងរៀបចំកិច្ចពិគ្រោះយោបល់នយោបាយលើកទី៣ រវាងក្រសួងការបទេស ទាំងពីរ ក្នុងឆ្នាំ២០២៧ នៅព្រះរាជាណាចក្រកម្ពុជា។

ឯកឧត្តម ថៃ ជុន បានសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសិង្ហបុរីជាម្ចាស់ផ្ទះសម្រាប់ការទទួលស្វាគមន៍យ៉ាងកក់ក្តៅ និងផ្តល់បដិសណ្ឋារកិច្ចយ៉ាងជិតស្និទ្ធចំពោះគណៈប្រតិភូកម្ពុជានៅក្នុងអំឡុងពេលស្នាក់នៅប្រទេសសិង្ហបុរី និងការរៀបចំកិច្ចពិគ្រោះយោបល់នយោបាយលើកទី២ រវាងក្រសួងការបរទេសទាំងពីរបានយ៉ាងល្អឥតខ្ចោះ។

ថ្ងៃ អង្គារ ១៥កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០២៥